ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ............សហវ.......

ថ្ងៃ..................ខែ.......... ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ.......ឆ្នាំ ២០១៩

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសំណើសុំកែសម្រួលប្រាក់ឧបត្ថម្ភគណៈកម្មការនានាក្នុងមណ្ឌលកំណែសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចាប់ពីឆ្នាំ ២០១៩ តទៅ ។

**យោង៖** -លិខិតលេខ២៥៨៥ អយក.ហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា

-ប្រកាសអន្តរក្រសួងលេខ ០១៦ សហវ.ប្រក. ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៨ ស្តីពីគោលការណ៍សម្រាប់ចំណាយលើការប្រឡងមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍ ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាបថា ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅលើកទឹកចិត្ត និងបង្កើនប្រសិទ្ធភាពការងាររបស់គណៈកម្មការនៅក្នុងមណ្ឌលកំណែនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចាប់ពីឆ្នាំសិក្សា២០១៨-២០១៩ តទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកភាពជាគោលការណ៍ ដូចខាងក្រោម ÷

១- ដំឡើងប្រាក់ឧបត្ថម្ភជូនអនុប្រធានមណ្ឌលកំណែឱ្យដល់ចំនួន ៨៦៥ ០០០រៀល/ម្នាក់

២- ដំឡើងប្រាក់ឧបត្ថម្ភជូនប្រធានក្រុមមុខវិជ្ជា ឱ្យដល់ចំនួន ៨៦៥ ០០០រៀល/ម្នាក់

៣- ដំឡើងប្រាក់ឧបត្ថម្ភជូនអនុប្រធានក្រុមមុខវិជ្ជា ឱ្យដល់ចំនួន ៧៦៥ ០០០រៀល/ម្នាក់ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

រីឯសំណើសុំកែសម្រួលប្រាក់ឧបត្ថម្ភគណៈកម្មការនានាចាប់ពីចំណុច ៤-១៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមរក្សាទុកតាមអត្រាឧបត្ថម្ភដែលមានក្នុងប្រកាសលេខ ០១៦ សហវ.ប្រក. ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៨ ស្តីពីគោលការណ៍សម្រាប់ចំណាយលើការប្រឡងមធ្យមសិក្សាចំណេះទូទៅនិងបំពេញវិជ្ជា ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍ ដដែល ។

ចំពោះនីតិវិធីចំណាយ និងវិធានក្នុងការអនុវត្ត ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមស្មារតីដែលមានចែងក្នុងប្រកាសអន្តរក្រសួងលេខ ០១៦ សហវ.ប្រក. ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៨ ស្តីពីគោលការណ៍សម្រាប់ចំណាយលើការប្រឡងមធ្យមសិក្សាចំណេះទូទៅនិងបំពេញវិជ្ជា ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍ ជាធរមាន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តម** ជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន៖</u>**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ